# ចម្លាក់សោមស្កន្ទក្នុងសិល្បៈខ្មែរ

សោមស្កន្ទ គឺជាទម្រង់ជាក់លាក់មួយដែលតំណាងឱ្យព្រះសិវៈ ហើយអ្នកតែងគោរពបូជាទ្រង់ គឺព្រះនាងឧមា និងព្រះស្កន្ទកាលពីក្មេង។ ការពិពណ៌នាអំពីក្រុមគ្រួសារព្រះសិវៈ គឺមានដើមកំណើតនៅឥណ្ឌាខាងត្បូងតាំងពីសតវត្សទី៦នៃគ.សមក។ តាមចម្លាក់នានាក្នុងសិល្បៈខ្មែរបានបង្ហាញទម្រង់ព្រះសិវៈមានដៃ៤ និងព្រះនាងឧមា ហើយនៅចន្លោះទ្រង់ទាំងពីរជាទារកស្កន្ទ។ ចម្លាក់សោមស្កន្ទ បានបង្ហាញក្នុងសិល្បៈខ្មែរយ៉ាងហោចណាស់ពីដើមសម័យអង្គរ ឧទាហរណ៍ចម្លាក់នៅពើងត្បាល់ ពើងឥសី និងចម្លាក់ទោលពីថ្មភក់ និងលោហធាតុ (រូបលេខ១)។ អត្ថបទនេះនឹងបង្ហាញពីការប្រៀបធៀបទេវកថាតិចតួចជាមួយឥណ្ឌា និងប្រៀបធៀបចម្លាក់ខ្មែរនៅលើភ្នំគូលែន និងប្រាសាទកោះកេរ។ ដោយសារខ្វះពត៌មានក្នុងសិលាចារឹក និងចម្លាក់នៅមុនសម័យអង្គរ និងដើមសម័យអង្គរ ទើបការសរសេរនេះបង្ហាញតែចម្លាក់៣ទីតាំងមកបកស្រាយ។

ចម្លាក់រូបសោមស្កន្ទ ដែលបង្ហាញជារូបកុមារស្កន្ទនៅចន្លោះព្រះសិវៈ និងព្រះនាងឧមា ក្នុងគោលបំណងដើម្បីបញ្ជាក់ពីសារៈសំខាន់របស់កុមារ ដែលមានបង្ហាញជាផ្ទាំងគំនូរនៅតាមិលឥណ្ឌាខាងត្បូងក្នុងគម្ពីរបុរាណ។ ក្រោយមកការគោរពសោមស្កន្ទមុរតិ (Somāskandamūrti) គេមើលឃើញថា ជាការសង្កត់ធ្ងន់ទៅលើការថ្វាយបង្គំព្រះស្កន្ទដែលតំណាងឱ្យព្រះសិវៈ និងព្រះនាងឧមាវិញ។

ចំណុចនេះនឹងបង្ហាញរឿងរាវសង្ខេបទាក់ទងកំណើតព្រះស្កន្ទ និងសោមស្កន្ទរបស់ឥណ្ឌា។ ការនិទានជាភាសាសំស្ក្រឹតដែលបានកត់ត្រាក្នុងសៀវភៅ នេះគឺជាប្រភពឯកសារមួយដ៏សំខាន់សម្រាប់ការយល់ដឹងអំពីវប្បធម៌ហិណ្ឌូក្នុងគម្ពីរបុរាណ។ ជាទូទៅគម្ពីរបុរាណពិពណ៌នាថាព្រះស្កន្ទជាកូនប្រុសរបស់ព្រះសិវៈ។ នៅពេលដែលព្រះសិវៈ និងនាងឧមាមានសេចក្តីរីករាយ ពេលនោះឋានសួររំខានដោយអសុរ(អារក្ស) ពេលនោះអ្នកតំណាងព្រះអគ្និស(ភ្លើង)បានទៅសុំការការពារពីព្រះសិវៈ។ នៅពេលដែលព្រះសិវៈមានការរំខាន

អត្ថបទដោយ៖ ថូ ថុន

នៅក្នុងការធ្វើសមាធិករបស់គាត់ ញើសរបស់គាត់បានស្រក់លើដី ហើយទ្រង់ឱ្យព្រះអគ្និសលេបវា ប៉ុន្តែគាត់មិនអាចរក្សាទុកវាបាន ហើយក៏លែងវាទៅក្នុងទន្លេគង្គា។[៧]

យោងតាមគម្ពីមតស្យបុរាណ គឺមានគ្រាប់ពូជរបស់ព្រះសិវៈត្រូវបាននាំមកដោយព្រះនាងឧមា ហើយបន្ទាប់មកបានច្រានចេញ និងទទួលដោយព្រះអគ្និ។ បន្ទាប់មកអ្នកបំរើស្រីក្ឫត្តិកា (Krttikā) ទាំង៦នាក់បានផឹកវា ហើយបានផ្តល់វាទៅឱ្យព្រះនាងឧមាពរពោះវិញ។ ប៉ុន្តែទារកនោះបានកើតចេញពីផ្ទៃកខាងស្តាំរបស់ព្រះនាងឧមា។ ព្រះស្កន្ទកើតមកជាក្មេងប្រុសដ៏អស្ចារ្យ មានព្រះកេសចំនួន៦ និងប្រដាប់ដោយអាវការពារ និងអាវុធសតិ។ ព្រះស្កន្ទត្រូវបានគេលើកតម្កើងដោយព្រះទាំងអស់ ហើយព្រះស្កន្ទបានសម្លាប់អសុរតារក។ ព្រះវិស្ណុផ្តល់ឱ្យអាវុធផ្សេងៗ ព្រះអគ្និប្រទានពរដល់គាត់ដោយភាពរុងរឿង និងព្រះវាយុឱ្យគាត់នូវយានជំនិះ ហើយគាត់ត្រូវបានគេលើកតម្កើងដោយព្រះធំៗទាំងអស់។ បន្ទាប់មកព្រះស្កន្ទបានរៀបការជាមួយទេវសេនាកូនរបស់ព្រះឥន្ទ្រ ប៉ុន្តែក្នុងគម្ពីស្កន្ទបុរាណបាននិយាយថារៀបការជាមួយសេនាកូនរបស់ព្រះយម ដែលជាទេពនៃសេចក្តីស្លាប់។

ចម្លាក់រូបសោមស្កន្ទ ដែលចាប់ផ្តើមពេញនិយមឆ្លាក់នៅសម័យដើមសតវត្សទី១០នៃគ.ស នៅពើងត្បាល់ ពើងគំនូរ និងនៅប្រាសាទក្រចាប់កោះកេរប្រហែលគ្នានឹងសម័យកាលវិវត្តន៍រូបព្រះស្កន្ទថ្មីៗនៅប្រទេសឥណ្ឌាខាងត្បូងដែរ។ ចម្លាក់សោមស្កន្ទមានកាយវិការផ្សេងពីនេះទៀត គឺចម្លាក់រូបព្រះស្កន្ទឈរ និងព្រះសិវៈអង្គុយក្នុងរចនាបថកោះកេរដ៏មានសារៈសំខាន់(រូបលេខ២)។ តាមចម្លាក់នៅឥណ្ឌាចាប់ផ្តើមឆ្លាក់រូបសោមស្កន្ទនេះតាំងពីសតវត្សទី៦រហូតសតវត្សទី១៣នៃគ.ស។ ប៉ុន្តែចម្លាក់នៅខ្មែរឃើញមានឆ្លាក់នៅដើមសម័យអង្គរនៅភ្នំគូលែន ជាពិសេសក្នុងសតវត្សទី១០-១១នៃគ.ស និងបន្តមកសម័យក្រោយៗទៀត។ បដិមាទោលទាំងរូបព្រះសិវៈ នាងឧមា និងស្កន្ទរកឃើញនៅពើងត្បាល់ ពើងគំនូរ និងប្រាសាទក្រចាប់កោះកេរ គឺជាបដិមាខ្មែរមានការគោរពយ៉ាងសំខាន់ក្នុងសម័យអង្គរ តែពុំសូវមានគោរពនៅសម័យមុនអង្គរនោះទេ។ ប៉ុន្តែមានចម្លាក់នៅលើភ្នំគូលែនដូចជាចម្លាក់នៅពើងត្បាល់ និងពើងគំនូរ ដែលបង្ហាញរូបព្រះសិវៈ នាងឧមា ព្រះស្កន្ទ និង

---

៧ Nagaswamy 1983

ព្រះគណេសធ្លាក់ក្បែរគ្នា។ ចម្លាក់សោមសូត្រមួយចំនួនប្រហែលធ្លាក់មុន និងមួយចំនួនទៀតធ្លាក់ក្រោយសម័យកោះកេរក្នុងសតវត្សទី១០នៃគ.ស (រូបលេខ៣-៦)។

ចម្លាក់និងរឿងទេវកថានៅប្រាសាទឥណ្ឌាខាងត្បូងព្រះសូត្រ គឺក្នុងកាយវិការអង្គុយដែលមានមុខក្មេងជាងទេពផ្សេងៗ។ ប្រាសាទមួយនៅតំបន់ Kāñcipuram ឥណ្ឌាខាងត្បូង គឺមានផ្ទាំងគំនូររឿងសោមសូត្រនៅលើជញ្ជាំង ដែលបង្ហាញការអង្គុយលើភ្លៅម្ដាយរបស់គាត់ និងមើលទៅព្រះសិវៈដោយក្ដីគោរព។ រហូតដល់សម័យចុលឡាឥណ្ឌាផ្នែកខាងត្បូង មានចម្លាក់សោមសូត្រពីសំរឹទ្ធដ៏ច្រើន ដែលគេបង្ហាញក្នុងឥរិយាបថអង្គុយ និងរាំក្នុងសតវត្សទី៩ និងទី១០នៃគ.ស។ គ្រឿងតុបតែងលម្អនៅខាងមុខត្រូវបានបង្ហាញយ៉ាងល្អជាងមុនដែលដៃស្ដាំងកាន់ផ្កាឈូក ហើយដៃខាងឆ្វេងដូចក្នុងកាយវិការវរទ។

សរុបសេចក្ដីមកចម្លាក់រឿងសោមាសូត្រខ្មែរពេញនិយមធ្លាក់នៅសម័យអង្គរ គឺតាមពើងក្បាលមាន២កន្ទែង ពើងគំនូរ និងនៅកោះកេរ។ ប៉ុន្តែចម្លាក់រឿងទេវកថាខ្មែរដែលមានការវិវត្តន៍ថ្មីច្រើនក្នុងស្នាមព្រះហស្តព្រះបាទជ័យវរ្ម័នទី៤ ដែលរឿងសោមាសូត្រជារឿងមួយក្នុងចំណោមរឿងសិវៈមហាស្វរមុរតិទាំង២៥របស់សទាសិវៈ ឬបរមេស្វរ (Parameśvara) នៅក្នុងគម្ពីសិវៈនិកាយ។ នៅប្រាសាទធំកោះកេរ ឧទាហរណ៍មួយចំនួនដូចជារឿង ឧមាមហេស្វរ ហរិហរៈ សិវៈរាំ ឯកបទ និងសោមសូត្រនេះជាដើម។ល។[២] ប៉ុន្តែចម្លាក់សោមសូត្រទាំងនៅកោះកេរ និងភ្នំគូលែន គឺជារឿងទាក់ទងទៅនឹងទេពមួយក្នុងចំណោមរឿងសិវៈមហាស្វរមុរតិទាំង២៥រឿង ដែលឃើញមានបង្ហាញច្រើនក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៤ និងបុត្ររបស់ព្រះអង្គ។ ឧទាហរណ៍មួយចំនួនដូចជារឿង ឧមាមហេស្វរ ហរិហរៈ សិវៈរាំ ឯកបទ និងសោមាសូត្រនេះជាដើម។ល។ ជាពិសេសរឿងនេះទាក់ទងនឹងព្រះសទាសិវៈឬបរមេស្វរនៅក្នុងគម្ពីសិវៈនិកាយ ដែលពេញនិយមធ្លាក់ច្រើនក្នុងសតវត្សទី១០នៃគ.ស។

[២] Sharma 1976: 3



***រូបលេខ១១៖*** *បដិមាសោមស្កន្ទ ជាមួយរូបព្រះស្កន្ទក្នុងកាយវិការរាំ នៅកណ្តាល ក្នុងសតវត្សទី១២នៃគស* (Anna, 2004: 37)



***រូបលេខ១២៖*** *បដិមារូបសិវៈ និងព្រះស្កន្ទ មានកំពស់ប្រហែល១.១២ម៉ែត្រ និងធ្វើពីថ្មភក់មកពីប្រាសាទក្រចាប់។ ព្រះស្កន្ទគឺ បង្ហាញរូបឈរចាប់ដៃព្រះសិវៈនៅចំពីមុខ ព្រះសិវៈអង្គុយសមាធិក*





***រូបលេខ១៣-១៤៖*** *បដិមារូបរួមគ្នា៣ព្រះនាងឧមាឬព្រះសិវៈជិះគោនៅកណ្តាល អមដោយខាងឆ្វេងរូបព្រះស្កន្ទ និងខាងស្តាំព្រះគណេសជាប្អូន។ រូបចម្លាក់បង្ហាញនៅពើងត្បាល់ចំនួន២កន្លែង (រូបលេខ១២* Chevance, 2013: 39)





***រូបលេខ១៥-១៦៖*** *បដិមារូបរួមគ្នាព្រះនាងឧមាឬព្រះសិវៈជិះគោនៅកណ្តាល អមដោយខាងឆ្វេងរូបព្រះស្កន្ទ និងខាងស្តាំព្រះគណេសជាប្អូន។ រូបចម្លាក់បង្ហាញនៅពើងត្បាល់ផ្នែកខាងលើ។*

*អត្ថបទដោយ៖ ប៉ូ ប៊ុន*

## ឯកសារយោង


Anna L. Dallapiccola

2004.“*Dictionary of Hindu Lore and Legend*”, American, Thames & Hudson.

Chevance Jean-Baptiste

2013. Poeng Tbal et Poeng Eisei ermitages Angkoriens meconnus du Phnom Kulen, Aseanie 32.

Nagaswamy, R

1983. Masterpieces of Early South Indian Bronzes, New Delhi.

Sharma B.N.

1976. “*Iconography of Sadasiva*” Abhinav Publications, pp. 1–3.


អត្ថបទដោយ៖ ចូ ចុន